# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IIB : ផលិតភាព និងពិពិធកម្មកសិកម្ម

## ថ្លែងដោយលោកជំទាវ Margaret Adamson ឯកអគ្គរាជទូតនៃប្រទេសអូស្ត្រាលីប្រចាំនៅកម្ពុជា តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**ភ្នំពេញ ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១០**

សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!

ក្នុងនាមដៃគូអភិវឌ្ឍន៍ យើងខ្ញុំសូមចូលរួមមតិពាក់ព័ន្ធទៅនឹងអាទិភាពសំខាន់ៗមួយចំនួនក្នុង វិស័យកសិកម្ម ។ គោលបំណងរបស់យើងខ្ញុំនាពេលនេះ គឺការពិភាក្សាជាមួយរាជរដ្ឋាភិបាល កម្ពុជាទៅលើសកម្មភាពអាទិភាពសំខាន់ៗ មួយចំនួនដែលដៃគូអភិវឌ្ឍន៍មានបំណងគាំទ្រដល់រាជរដ្ឋាភិបាល ។ ហើយនេះក៏ជាការប៉ាន់ប្រមាណរបស់យើងខ្ញុំផងដែរថា សកម្មភាពទាំងអស់នេះ នឹងជំរុញកំណើនផលិតភាពនិងពិពិធកម្មកសិកម្មព្រមទាំងបង្កើនការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជា ស្របតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទីពីរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រកសិកម្ម និងទឹក ។

មុននឹងធ្វើការភិភាក្សាទៅលើសកម្មភាពអាទិភាព យើងខ្ញុំសូមកោតសរសើរចំពោះការរីកចំរើនជាលំដាប់នៃ វិស័យកសិកម្ម ដែលជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ចជាតិ ។ ខណៈពេលដែលវិស័យផ្សេងៗទៀតមានការថយចុះ ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក អត្រាកំណើនផលិតផលសរុបក្នុងស្រុកនៃវិស័យកសិកម្មបានកើនដល់ ៥,៤% ក្នុងឆ្នាំ ២០០៩ ។ សមាសភាគនៃវិស័យកសិកម្មនៅក្នុងផលទុនសរុបជាតិ (GDP) បានកើនពីអត្រា២៩.៧% ក្នុងឆ្នាំ ២០០៧ ទៅដល់៣៣.៥%ក្នុងឆ្នាំ២០០៩ ។ នេះសរបញ្ជាក់អោយឃើញថា ភាពចាំបាច់នៃការបន្តកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម គឺជាប្រភពចំបងនៃកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើតផលិតភាពនិងពិពិធកម្ម និងភាពធន់ចំពោះការប្រែប្រួលអាកាសធាតុ ។ ជាងនេះទៅទៀតយើងខ្ញុំសំគាល់ឃើញថា មានការសមារណកម្មស្ត្រីយ៉ាងខ្លាំងក្លាទៅក្នុងវិស័យកសិកម្ម ដែលមានសារៈសំខាន់ចំពោះ វិស័យសេដ្ឋកិច្ចនិងសងមកិច្ចជាតិ យើងខ្ញុំសូមកោតសរសើរដល់រដ្ឋាភិបាល ដែលបានប្រឹងប្រែងយកចិត្តទុកដាក់លើបញ្ហានេះ ។

យើងខ្ញុំក៏សូមកោតសរសើរផងដែរដល់រាជរដ្ឋាភិបាលអំពីសមទ្ធិផលដែលបានសំម្រេចបាន**ក្នុងការបង្កើនផលិភាពកសិកម្ម** ជាពិសេសផលិតកម្មស្រូវ។ ទិន្នផលស្រូវបានបន្តកើនកំណើនពីចំនួន ២.៧៤តោន/ហត ក្នុងឆ្នាំ២០០៨ ទៅដល់ចំនួន ២.៨៣តោន/ហត ក្នុងឆ្នាំ២០០៩។ រីឯផ្ទៃដីដំណាំស្រូវក៏បានកើនឡើងក្នុងអត្រា ៥.៧% ក្នុងឆ្នាំ ២០០៩ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨។

ក្រៅពីនិន្នាការវិជ្ជមាន និងសក្តានុពលក្នុងវិស័យកសិកម្មឧបស័គ្គសំខាន់ៗមួយចំនួន នៅបន្តមានក្នុងបន្ថយគម្លាតឧត្តមភាពប្រកួតប្រជែងនៃវិស័យកសិកម្មរវាងប្រទេសកម្ពុជានិងប្រទេសជិតខាង។ កំណើននៃសកម្មភាពកសិកម្មមានការពឹងផ្អែកស្ទើរទាំងស្រុងទៅលើប្រភពទឹកភ្លៀង ប៉ុន្តែវាងាយរងគ្រោះនៅពេលដែលមានការលេចឡើងនូវសត្វល្អិតបំផ្លាញ ភាពរាំងស្ងួត និងទឹកជំនន់។ ដំណើរនៃកំណើនផលិតភាពកសិកម្មតែងតែមាន ការរារាំងពីកង្វះទឹកស្រោចស្រព បច្ចេកទេសនៅមានកំរិតទាប ការប្រើប្រាស់វត្ថុធាតុដើមពុំទាន់ត្រឹមត្រូវ និងមានការខ្វះខាតទំនាក់ទំងទីផ្សារ។ ហេតុដូច្នេះឧបស័គ្គចំបងដែលយើងត្រូវជំនះ គឺធានាឱ្យបាននូវសន្តិសុខស្បៀងសម្រាប់អ្នករងគ្រោះ តាមរយៈការពង្រឹងភាពធន់នឹងហានិភ័យ និងការ បង្កើតឧត្តមភាព ប្រកួតប្រជែង។

ដោយផ្អែកទៅលើសមទទ្ធិផល ដែលសម្រេចបាន និងឧបស័គ្គដែលកកំពុងជួប ដៃគូអភិវឌ្ឍន៍ប្តេជ្ញាចិត្តបន្តការគាំទ្រដល់រាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៏វិស័យកសិកម្មឱ្យក្លាយទៅជាកម្លាំងចលករ នៃកំណើនសដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ ដៃគូអភិវឌ្ឍន៍សូមអបអរសាទរដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ចំពោះយុទ្ធសាស្រ្តកសិកម្ម និងទឹកដែលទើបតែអនុម័ត។ យុទ្ធសាស្រ្តកសិកម្មនិងទឹក ផ្តល់នូវក្របខ័ណ្ឌដ៏សំខាន់មួយសម្រាប់ឱ្យយើងក្នុងការរៀបចំផែនការកម្មវិធី និងអនុវត្តន៏ក្នុងវិស័យកសិកម្ម។ ចំពោះកិច្ចពិភាក្សា នាថ្ងៃនេះ យើងសូមផ្តោតការយកចិត្តទុកដាក់ ទៅលើអាទិភាពចំបងចំនួនបី មាន ដូចខាងក្រោម :

**អាទិភាពទី១** គឺការបង្កើនសុខដុមកម្ម និងភាពស៊ីសង្វាក់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍ដើម្បីអនុវត្តយុទ្ធសាស្រ្តកសិកម ្មនិងទឹក។ បញ្ហានេះនឹងទាមទារឱ្យមានភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវធ្វើដំណើររួមគ្នាមួយនឹងកិច្ចសហប្រត្តិបត្តិការ និងគាំទ្រពីដៃ គូអភិវឌ្ឍន៍។

ការបង្កើនវិនិយោគក្នុងវិស័យកសិកម្ម គឺជាតំរូវការមួយទៀតផងដែរ។ ដូចប្រសាសន៏របស់សម្តេចនាយក រដ្ឋមន្រ្តី ហ៊ុន សែន បានគូសបញ្ជាក់ក្នុងពិធីសម្ភោធដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី២ ហើយថាការកើនឡើង នូវតំលៃស្បៀងអាហារទាមទារអោយមានការបង្កើនវិនិយោគទុនក្នុងវិស័យកសិកម្ម ដើម្បីលើក

ស្ទួយផលិតភាពកសិកម្ម និងសន្តិសុខស្បៀង។ យោងតាមលទ្ធផលនៃការត្រួតពិនិត្យនូវវិស័យកសិកម្ម ធារាសាស្ត្រ ផ្លូវថ្នល់ជនបទ និងការចំណាយសាធារណៈបច្ចុប្បន្ន បានបញ្ជាក់ថាបញ្ហាតម្លៃ ស្បៀងឡើងថ្លៃបានធ្វើឱ្យចំណាយសាធារណៈ ក្នុងវិស័យកសិកម្មកើនឡើងទ្វេដង។

ដៃគូអភិវឌ្ឍន៍ប្តេជ្ញាគាំទ្ររាជរដ្ឋាភិបាលកម្ពុជា អនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹកដែលជាការវិនិយោគដ៏សំខាន់មួយ ដើម្បីបង្កើនផលិតភាពកសិកម្ម។ ការចូលរួមថវិការបស់ដៃគូអភិវឌ្ឍន៍ ចំពោះវិស័យកសិកម្ម កម្ពុជាមានកំរិត ពី ៣៤ ទៅដល់៥៤លានដុល្លារ សហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ ២០០០-២០០៨ ដែលទំហំថវិកាវិនិយោគនេះមានការកើនឡើងជាលំដាប់។ **ដៃគូអភិវឌ្ឍន៍ប្រាថ្នាស្វែងរកវិធីសាស្ត្រល្អៗដើម្បីចូលរួមរៀបចំផែនការផ្តល់ហិរញ្ញវត្ថុ អនុវត្តតាមដានពិនិត្យ និងវាយតម្លៃនៅក្នុងវិស័យដែលភាគីដៃគូអភិវឌ្ឍន៍ និងភាគីរាជរដ្ឋាភិបាលចាប់អារម្មណ៍** ។ យើងខ្ញុំចាត់ទុកប្រព័ន្ធធារាសាស្ត្រ និងការស្រាវជ្រាវនិងផ្សព្វផ្សាយ គឺជាវិស័យសំខាន់ពិសេសពីរដែលសមនឹងបង្កើនការគាំទ្រ។

ការពង្រីក**ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ** គឺជាការគាំទ្រកំណើនផលិតភាពពិតកម្មកសិកម្ម។ ទោះជាយ៉ាងនេះក្តី ការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ**ត្រូវតែមានតុល្យភាពជាមួយនឹងចំណាយទៅលើការប្រត្តិបត្តិនឹងការថែទាំ**។ នេះគឺជាកត្តាសំខាន់ដើម្បីកាត់បន្ថយការចំណាយទៅលើការស្តារប្រព័ន្ធឡើងវិញដែលមានតម្លៃថ្លៃ។ លទ្ធផលត្រួតពិនិត្យឡើងវិញនូវការចំណាយសារធារណៈ ផ្តល់ជាអនុសាសន៍ថា ការចំណាយទៅលើការថែទាំ ប្រព័ន្ធធារាសាស្ត្រគួរមានទំហំ ប្រមាណមួយភាគបីនៃចំនួនចំណាយសរុប។ ទោះជាយ៉ាងនេះក៏ដោយក៏ថវិកាថែមទាំ បច្ចុប្បន្ននៅមានកំរិតទាបជាងនៅឡើយ។ សូម្បីតែនៅក្នុងពេលមានវិបត្តិស្បៀងឡើងថ្លៃ ក៏តម្លៃសេវាធារាសាស្ត្រមាន ពុំគ្រប់គ្រាន់សំរាប់ការប្រត្តិបត្តិ និងការថែទាំប្រឡាយរងផងដែលនេះទាមទារឱ្យមានការបំពេញបន្ថែម។

យើងខ្ញុំសូមស្នើរាជរដ្ឋាភិបា**លបំភ្លឺអំពីការរៀបចំស្ថាប័ននឹងគោលនយោបាយសំរាប់ការប្រត្តិបត្តិ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ រួមទាំងតួនាទីរបស់សហគមន៍ប្រើប្រាស់ទឹក**។ យើងក៏សូមស្នើរាជរដ្ឋាភិបាលពិនិត្យ**ដកថវិកាមួយចំនួនពីការស្តាហេដ្ឋារចនាសម្ព័ន្ធមកបំពេញឱ្យការថែទាំហេដ្ឋារចនាសម្ព័ន្ធវិញ** ដើម្បីការពារការខូចខាតមុនអាយុកាល។

ការរីកចំរើនក្នុងផលិតភាពកសិកម្ម និងប្រពលវប្បកម្មគឺជាលទ្ធផល ដែលបានមកពីការវិនិយោគដ៏មានប្រសិទ្ធិភាព ក្នុងការស្រាវជ្រាវនិងការផ្សព្វផ្សាយ ព្រមទាំងពីសន្ទរកថាក្នុងពិធីបុណ្យខួប១០ឆ្នាំ របស់វិទ្យាស្ថានអភិវឌ្ឍន៍និងស្រាវជ្រាវកសិកម្ម (CARDI) យើងខ្ញុំយល់ថា ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រាថ្នាចង់ឃើញសកម្មភាពបន្ថែមទៀតនៅក្នុងវិស័យកសិកម្ម។ កាលានុវត្តភាពជាច្រើន មានសំរាប់បង្កើនប្រសិទ្ធភាពតម្លៃក្នុងការគាំទ្រពីរាជរដ្ឋាភិបាលចំពោះ**ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម។** ចំពោះការចំណាយ

របស់កសិកម្មបច្ចុប្បន្ន យើងខ្ញុំកត់សំគាល់ឃើញថា ចំនួនថវិកាតិចជាង៥% ត្រូវបានចំណាយសំរាប់ការស្រាវជ្រាវនិងតិចជាង៣%សំរាប់ការផ្សព្វផ្សាយ ។ ទំនាក់ទំនងរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយកសិករ និងទីផ្សារត្រូវតែទទួលបាននូវការពង្រឹង ដើម្បី សម្រួលដល់ការទទួលយកបាននូវបច្ចេកវិទ្យាថ្មីៗ ។ ឧទាហរណ៏ ដូចជាការជំរុញឱ្យមានការប្រើប្រាស់ជី និងថ្នាំកំចាត់ សត្វល្អិតត្រឹមត្រូវ ព្រមទាំងព័តិមានទីផ្សារជាក់លាក់ជាដើម ដើម្បីរក្សានូវកំណើនទិន្នផល និងបរិមាណផលឱ្យមាន និរន្តរភាព ។

កំណើនក្នុងចំណាយសាធារណៈទៅលើធារាសាស្រ្ត ស្រាវជ្រាវ និងផ្សព្វផ្សាយ មានសារៈសំខាន់ចំពោះការបន្សាំទៅនឹងភាពរាំងស្ងួត ទឹកជំនន់ និងរដូវភ្លៀងខ្លី ដោយសារការប្រែប្រួលអាកាសធាតុ ។ ការបន្សាំទៅនឹងផលប៉ះពាល់ទាំងនេះ នឹងទាមទារឱ្យមានអាងស្តុកទឹក ប្រព័ន្ធធារាសស្រ្ត និងការអភិវឌ្ឍន៍បច្ចេកទេសដាំដុះ និងពូជ ។ យើងខ្ញុំស្នើក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បញ្ចូលបន្ថែមនូវវិធានការណ៏បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួមទាំងកម្មវិធីសកម្មភាពបន្សាំថ្នាក់ជាតិចំពោះការប្រែប្រួលអាកាសធាតុ **(NAPA)**[1] ទៅក្នុងយុទ្ធសាស្រ្តកសិកម្ម និងទឹក ។ ដៃគូអភិវឌ្ឍន៍ សូមកោតសរសើរចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមកិច្ចព្រមព្រៀងទីក្រុងកូប៉េនហាក់ (Copenhagen Accord) និង REDD[2] + Agreement កម្ពុជាអាចទាក់ទាញវិនិយោគបរទេស នៅពេលដែលយើងកំពុងចូលរួមយ៉ាងពិតប្រាកដ ក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ។ វិស័យកសិកម្មមានជាអាទិ៍ៈ ការថែទាំធនធានព្រៃឈើ ការការពារ មច្ឆាជាតិ និងការមានទឹកស្រោចស្រពដំណាំ គឺមានទំនាក់ទំនងយ៉ាងជិតស្និទទៅនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកប ដោយនិរន្តរភាព និងស្ថេរភាពពេលអនាគតក្នុងកម្ពុជា និងក្នុងតំបន់អាងទន្លេមេគង្គទាំងមូល ។

ស្របជាមួយនឹងសូចនាករនៃការត្រួតពិនិត្យរួម **(JMIs)** សម្រាប់យុទ្ធសាស្រ្តកសិកម្ម និងទឹក ដៃគូអភិវឌ្ឍន៍ សូមស្នើសុំឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងធនធានទឹក និងឧតុនិយម សហការណ៏ក្នុងការបង្កើតផែនទីបង្ហាញផ្លូវដើម្បីអនុវត្តន៍យុទ្ធសាស្រ្តកសិកម្ម និងទឹក រួមជាមួយដៃគូអភិវឌ្ឍន៍ **ដើម្បីកំណត់អទិភាពសម្រាប់ការចំណាយសាធារណៈដែលនឹងត្រូវបង្កើន ដូចជាការចំណាយលើការប្រត្តិបត្តិ**

[1] National Adaptation Programme of Action
[2] Reduced Emissions from Deforestation and Forest Degradation

**និងការថែទាំហេដ្ឋា រចនាសម្ព័ន្ធធារាសាស្ត្រ ព្រមទាំងការស្រាវជ្រាវ និងការផ្សព្វផ្សាយ** ។ បន្ទាប់មក ព័ត៌មានទាំងអស់នេះ អាចត្រូវ បានប្រើប្រាស់ដើម្បីជូនដំណឹងដល់**ផែនការចំណាយរយៈពេលមធ្យម (MTEF) និង ផែនការថវិកាយុទ្ធសាស្ត្រ (BSP) សម្រាប់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងធនធានទឹក និងឧតុនិយម ដើម្បីរៀបចំផែនការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍យុទ្ធសាស្ត្រកសិកម្ម និងទឹក**។ ថ្ងៃនេះ យើងខ្ញុំសូនស្នើយោបល់ពីក្រសួងទាំងបីខាងលើ អំពីថាតើកិច្ចការនេះត្រូវធ្វើតាមវិធីណាដើម្បីទទួលបាន នូវលទ្ធផលល្អបំផុត ។

**អាទិភាពទី២** ដៃគូរអភិវឌ្ឍន៏មានចំណងចង់ពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានាថ្ងៃនេះផងដែរ គឺការ **ធានាសុវត្ថិភាពកម្មសិទ្ធដីខ្នាតតូច និងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានដីរបស់រដ្ឋ ។** សុវត្ថិភាពកម្មសិទ្ធដី និងការគ្រប់គ្រងធនធានដីរបស់រដ្ឋប្រកបដោយប្រសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះដើម្បីបង្កើនផលិតភាព និងពិពិតកម្មកសិកម្ម សម្រាប់កំណើនសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្រ និរន្តរភាពនៃធនធានធម្មជាតិក្នុង កំឡុងពេលដែលមាន កំណើនប្រជាជន និងជាមួយស្ថានភាពដែលកំពុងមានអាកាសធាតុប្រែប្រួល ។ ខណៈពេលដែល កត់សំគាល់ឃើញ ពីដំណើរការទៅមុខនៃការចេញកម្មសិទ្ធដីកសិករកាន់កាប់ដីទំហំតូច ដីរដ្ឋដែលពុំទាន់មានព្រំដែន ច្បាស់លាស់ និង និតិវិធីពុំមានតម្លាភាពក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច នៅតែបន្តបង្កាក់ដល់អ្នកមានកម្មសិទ្ធដី តូចតាច និងកម្មសិទ្ធ ដីធ្លីសហគមន៏ ។ យើងខ្ញុំក៏សូមសំដែងនូវការព្រួយបារម្ភអំពីដំណើរការយឺតយ៉ាវនៃការធ្វើ សម្បទាណដីសង្គមកិច្ច និង សិទ្ធកាន់កាប់ដីធ្លីរបស់ជនជាតិភាគតិចផងដែរ ។

ដៃគូអភិវឌ្ឍន៏សូមជំរុញ និងឱ្យបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុង**ការអនុវត្តន៍ច្បាប់ភូមិបាលឆ្នាំ ២០០១** ដើម្បីធានា សន្តិសុខ និងការពារ **កម្មសិទ្ធដីតូចតាច និងសិទ្ធកាន់កាប់ដីរបស់ជនជាតិភាគតិច** ខណៈពេលដែលមានការរីកចំរើន នៃការគ្រប់គ្រងធនធានដីរដ្ឋ រួមទាំងការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងលក្ខណៈតម្លាភាព និងនិរន្តរភាពសម្រាប់ បរិស្ថាន និងសង្គម ។

ដោយគោរពទៅតាមកម្មសិទ្ធដីតូចតាច វាជាការសំខាន់ក្នុងការចាត់ជាអទិភាពនូវធនធានដែលមានសម្រាប់ប្រពន្ធ័កម្មសិទ្ធដី ក្នុងការគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងបង្កើនផលិតភាព។ ហេតុដូច្នេះយើងខ្ញុំសូមសួរទៅកាន់ក្រសួងដែនដី នគរូបណីយកម្ម និងសំណង់ ថាតើវិធីណាដែលអាចធ្វើឱ្យប្រសើរឡើងនូវកម្មសិទ្ធដីធ្លីសហគមន៍ និងដីសម្បទានសង្គមកិច្ចដល់ គ្រួសារក្រីក្រ និងងាយរងគ្រោះ ដើម្បីផ្តល់ដល់ពួកគាត់នូវកម្មសិទ្ធដីប្រកបដោយសុវត្ថិភាព និងជួយបង្កើនផលិតភាពកសិកម្មរបស់ពួកគាត់។

យើងខ្ញុំសូមកោតសរសើរដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការពិនិត្យ និងវាយតម្លៃលើដីសម្បទានសេដ្ឋកិច្ចទាំងអស់ និងវិធានការណ៍លុបចោល ឬកាត់បន្ថយផ្ទៃដីសម្បទានសេដ្ឋកិច្ចអសកម្មមួយចំនួនសម្រាប់ជាដីសម្បទានសង្គមកិច្ច។ យើងខ្ញុំសូមស្នើដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ពាក់ពន្ធ័នឹងដីសម្បទានសេដ្ឋកិច្ចបន្ថែមទៀត។ ក្នុងខណៈនេះផងដែរ យើងខ្ញុំសូមជំរុញដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធានាថា អ្នកកាន់កាប់ដីធ្លីតូចតាច និងសហគមន៍ រួមទាំងជនជាតិភាគតិចត្រូវបានការពារ និងលើកកំពស់។ ដើម្បីជូនជាព័ត៌មានដល់ការពិភាក្សាបន្ថែម អំពីវិធានការណ៍សមស្រប ដែលអាចគាំទ្រដោយដៃគូអភិវឌ្ឍន៍ យើងខ្ញុំសូមសុំយោបល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃនេះថាតើនៅពេលណាក្រសួងនឹងបញ្ចេញលទ្ធផលនៃការវាយតម្លៃដីសម្បទានសេដ្ឋកិច្ចទាំងអស់ (ដែលបានដាក់ជូន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ កាលពីខែមិថុនា ឆ្នាំ ២០០៩)។ យើងខ្ញុំកត់សំគាល់ឃើញនៅលើគេហទំព័ររបស់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទថា របាយការណ៍នេះ នឹងចេញក្នុងរយៈពេលពីរខែ។ ទន្ទឹមនឹងនេះផងដែរ យើងសូមស្នើសុំឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ជាក់អំពីទីកន្លែងសមស្របបំផុតសម្រាប់ការពិភាក្សាបន្តរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ទាក់ទងទៅនឹងដីសម្បទានសេដ្ឋកិច្ច។

**អាទិភាពចុងក្រោយ** ដៃគូអភិវឌ្ឍន៍មានបំណងពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានាថ្ងៃនេះ **គឺការបង្កើនឧត្តមភាពប្រកួតប្រជែង និងលទ្ធភាពទីផ្សារនៃផលិតផលកសិកម្មកម្ពុជា។** អនុលោមតាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅឯសិក្ខាសាលាប្រចាំឆ្នាំរបស់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងកិច្ចប្រជុំរដ្ឋាភិបាល និងវិស័យឯកជននាឆ្នាំនេះ ផលិតកម្មកសិកម្មចម្រុះ និងការអភិវឌ្ឍន៍ខ្សែសង្វាក់ផលិតកម្ម រួមទាំងដំណើរការនៃការកែច្នៃ

គឺមានលក្ខណៈសំខាន់ដើម្បីបង្កើនការលក់ក្នុងស្រុក និងការនាំចេញប្រកបដោយតម្លៃខ្ពស់។ វាជាការសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ជាក់ នឹងពង្រឹងតួនាទីស្ថាប័នពាក់ពន្ធ័ ដែលរដ្ឋាភិបាលអាចដើរតួនាទីក្នុងការជំរុញវិស័យឯកជនអោយមានភាពល្អប្រសើរឡើងក្នុងវិស័យកសិកម្ម និងទឹក។ តួនាទីបែបនេះ អាចរួមបញ្ចូលទាំងបទបញ្ញត្តិនានាប្រកបដោយប្រសិទ្ធភាពនៃទីផ្សារនាំចូលដើម្បីធានានូវធាតុចូលឱ្យ មានគុណភាពខ្ពស់ដែលអាចឱ្យកសិករទទួលបាននូវតម្លៃសមរម្យខណៈពេលដែលដាក់ឱ្យមាននូវការសម្របសម្រួល **ចែករំលែកភាពហានិភ័យឥណទានដើម្បីលើកកំពស់ការផ្តល់ប្រាក់កំចីរបស់ធានាគារពាណិជ្ជកម្មដល់ប្រតិបត្តិការ ម៉ាស៊ីនកិនស្រូវ**។

រាជរដ្ឋាភិបាលក៏អាចដើរតួនាទីសំខាន់ផងដែរដើម្បីគាំទ្រដល់វិស័យឯកជន ដោយបង្កើតនូវយន្តការអនាម័យ និងភូតគាមអនាម័យ (SPS) ដែលចាំបាច់សម្រាប់ការពារប្រជាជនកម្ពុជាពីអាហារដែលធ្វើឱ្យខូចសុខភាព និងសម្រាប់ការពារុក្ខជាតិ និងសត្វ ពីសត្វល្អិតបំផ្លាញ និងជំងឺ។ សុវត្ថិភាពអាហារមានលក្ខណៈខ្វះខាត និងសុខភាពសត្វ ចុះខ្សោយបណ្តាលឱ្យខូចសុខភាពសាធារណៈ កាត់បន្ថយផលិតភាពកសិកម្ម ដាក់កម្រិតដល់ការហូរចូល ទៅកាន់ទីផ្សារអន្តរជាតិសម្រាប់ការនាំចេញអាហារ និងភេសជ្ជៈពីប្រទេសកម្ពុជា។

ជាមួយនឹងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនៅក្នុងឆ្នាំ ២០០៤ ប្រទេសកម្ពុជាប្តេជ្ញាអនុវត្តយ៉ាងពេញលេញទៅតាមកិច្ចព្រមព្រៀង (SPS) ក្នុងកំឡុងពេលអន្តរកាលរយៈពេល ៥ឆ្នាំ។ បើទោះបី ជាយ៉ាងនេះក្តីគឺនៅមានភាពខ្វះខាតក្នុងយន្តការ (SPS) និងសុវត្ថិភាពចំណីអាហារ។ កង្វះខាត ទាំងនេះរួមមាន (១) ការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ពន្ធ័នឹង (SPS) និងសុវត្ថិភាពចំណីអាហារ (២) ការពង្រឹងសមត្ថភាពអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗដែលពាក់ពន្ធ័នឹងការពង្រឹង និងអនុវត្តន៍ច្បាប់ (SPS) និងសុវត្ថិភាពចំណីអាហារក្នុងដំណាក់ការនានានៃខ្សែសង្វាក់ផ្គត់ផ្គង់ និង (៣) ការ ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាកម្ម (SPS) ដូចជាមន្ទីរពិសោធន៍ដែលពាក់ពន្ធ័នឹងការវិភាគ (SPS) នឹងសុវត្ថិភាពចំណីអាហារ។ បទបញ្ញត្តិគ្រប់គ្រាន់ត្រូវតែមានផងដែរ ដើម្បីអនុលោមទៅតាមកិច្ចព្រមព្រៀង អន្តរជាតិរវាងប្រទេសនានានៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។

ការផ្តល់នូវសេវាកម្មទាក់ទងនឹង (SPS) ប្រកបដោយប្រសិទ្ធភាពដើម្បីលើកកំពស់វិស័យពាណិជ្ជកម្មឯកជន គឺជាគន្លឹះមួយនៃសូចនាករណ៍ត្រួតពិនិត្យរួម (JMIs) សម្រាប់ការអភិវឌ្ឍន៍វិស័យឯកជន។ យើងសូមអនុញ្ញាតិសួរថា តើរាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការប្តេជ្ញាចិត្តក្នុងការបង្កើតប្រកាសអន្តរក្រសួងដើម្បីបញ្ជាក់អំពីតួនាទី និងការទទួល ខុសត្រូវ ព្រមទាំងការសម្របសម្រួលក្នុងចំណោមស្ថាប័នដែលពាក់ពន្ធ័នឹង (SPS) ដើម្បីបញ្ច្រាបការ រៀបចំស្ថាប័ន បង្រួមតួនាទីជាន់គ្នា កាត់បន្ថយពេលវេលា និងតម្លៃអធិការកិច្ច និងបង្កើនយន្តការរាយការណ៍ សម្រាប់សុវត្ថិភាពចំណីអាហារដែរឬទេ?

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សម្រាប់ការយកចិត្តទុកដាក់ស្តាប់អំពីផែនការសកម្មភាពអាទិភាពនៅក្នុងវិស័យកសិកម្មពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍។
ដៃគូអភិវឌ្ឍន៍នៅតែរក្សាការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្តសកម្មភាពអាទិភាពទាំងអស់នេះ ហើយយើងខ្ញុំរងចាំដោយរីករាយដើម្បីពិភាក្សាបន្តថាតើយើងទាំងអស់គ្នាអាចសម្រេចកិច្ចការនេះ ឱ្យបានល្អបំផុតតាមរបៀបណាដើម្បីលើកកំពស់ផលិតភាព និងពិពិតកម្មកសិកម្ម ព្រមទាំងការបង្កើនកិច្ចអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកឱ្យមានភាពល្អប្រសើរនៅក្នុងប្រទេសកម្ពុជា។